លេខ ១ ខែ មករា ឆ្នាំ១៩៩០

# រដ្ឋកិច្ច

រួមមាន :

- ច្បាប់
- ក្រឹត្យ-ច្បាប់
- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ
- សារាចរណែនាំ

ផ្សាយចេញពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីជារៀងរាល់ខែ

Downloaded from http://www.khmerlaws.com

# មាតិកា

ទំព័រ

## I – ក្រុមប្រឹក្សារដ្ឋ

### ក្រឹត្យ


៣០-០១-៨០ ក្រឹត្យលេខ ១០ ក្រ ស្ដីពីការប្រមាណចំពោះសម្ភារការសិក្សាក្រសួងឧស្សាហកម្ម ១

៣០-០១-៨០ ក្រឹត្យលេខ ១១ ក្រ ស្ដីពីការតែងតាំងសមមិត្ត ម៉ឹង សំរ៉ាន ជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃរដ្ឋកម្ពុជា ប្រចាំនៅសាធារណរដ្ឋហុងគ្រីប្រជាមានិត និង សាធារណរដ្ឋ គុយបា ៣


## II – ក្រុមប្រឹក្សារដ្ឋមន្ត្រី

### ១ – អនុក្រឹត្យ


២០-០១-៨០ អនុក្រឹត្យលេខ ០២អនក្រ ស្ដីពីអត្រាម៉ោយ ម្ហូបអាហារ ៤


### ២– សេចក្ដីសំរេច


២២-០១-៨០ សេចក្ដីសំរេចលេខ ០៥ សសរ ស្ដីពីវិធីមូលនិធិគ្រប់ប្រភេទ ៥

១២-០១-៨០ សេចក្ដីសំរេចលេខ ០៨ សសរ ស្ដីពីការបង្កើត គ្រូពេទ្យ ៥

៣០-០១-៨០ សេចក្ដីសំរេចលេខ ១៨ សសរ ស្ដីពីការបង្កើតគណៈកម្មការត្រួតពិនិត្យការគ្រប់គ្រងសារពើពន្ធ របស់មូលដ្ឋាន ខេត្ត ក្រុង ១១


### ៣– សារាចរ


១៥-០១-៨០ សារាចរលេខ ០១ សរ ស្ដីពីការគ្រប់គ្រងគេហដ្ឋាន ដីធ្លី ដែលជួលនៅជាអង្គការអន្តរជាតិ ក្រុមហ៊ុន ឬ ជនបរទេស ១៣

២២-០១-៨០ សារាចរលេខ ០២ ស.រ ស្ដីពីការពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់ ស្ថិរភាពសង្គមនៅតាមបណ្ដា ខេត្ត-ក្រុង ទូទាំងប្រទេស ១៥


Downloaded from http://www.khmerlaws.com

# III – ការងារបណ្តាក្រសួង

## ក្រសួងឃោសនាការ វប្បធម៌

### សេចក្តីជូនដំណឹង

០៤ - ០១ - ៩០ សេចក្តីជូនដំណឹងលេខ ០១ សជណ ស្តីពីការអនុវត្តគោលការណ៍ការធ្វើ
អាជីវកម្ម នាំចេញ - នាំចូល និង ចែកបញ្ចាំងភាពយន្ត និង វីដេអូ ១៨

Downloaded from http://www.khmerlaws.com

# I - ក្រុមប្រឹក្សារដ្ឋ

## ក្រឹត្យ

## ក្រឹត្យ លេខ ១០ ក្រ.

## ក្រុមប្រឹក្សារដ្ឋ

## នៃរដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្ដីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្ដីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្ដីពីការការពារទ្រព្យសម្បត្តិរដ្ឋ ដែលប្រកាសអោយប្រើតាមក្រឹត្យ លេខ ១០ ក្រ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៨២

- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

- យោងកំណត់ហេតុ នៃសម័យប្រជុំសាមញ្ញក្រុមប្រឹក្សារដ្ឋ ថ្ងៃទី ២០ ខែមករា ឆ្នាំ ១៩៩០

## សំរេច

*មាត្រា១* .— ត្រូវព្រមានចំពោះសមូហភាពថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម លើកលែងតែ សមមិត្តនារី ហ៊ូ ណាន រដ្ឋមន្ត្រីបច្ចុប្បន្ន ។

ចំពោះសមមិត្ត មាស សំណាង រដ្ឋមន្ត្រីចូលនិវត្តន៍ ត្រូវរួចពីការដាក់វិន័យ ។

*មាត្រា ២* .— ត្រូវព្រមានចំពោះសមមិត្ត អ៊ិត ប្រាំង និង ខួត វ៉ាន់នី អនុរដ្ឋមន្ត្រី ក្រសួង ឧស្សាហកម្ម ។

Downloaded from http://www.khmerlaws.com

*មាត្រា ៣.—* ត្រូវស្ដីបន្ទោសចំពោះសមមិត្ត សុខ ឥសាន អនុរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម។

*មាត្រា ៤ .—* ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩០*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

Downloaded from http://www.khmerlaws.com

# ក្រឹត្យ លេខ ១១ ក្រ

## ក្រុមប្រឹក្សារដ្ឋ
## នៃរដ្ឋកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

## សំរេច

*មាត្រា ១.* – ត្រូវបានតែងតាំង សមមិត្ត អ៊ុង សារ៉ន ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃរដ្ឋកម្ពុជា ប្រចាំនៅសាធារណរដ្ឋហ្គីណេប៊ីស្សូ និងសាធារណរដ្ឋក្លុតឌីវ បន្ថែមលើមុខងារបច្ចុប្បន្ន ជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃរដ្ឋកម្ពុជា ប្រចាំនៅសាធារណរដ្ឋសង្គមនិយមឆេកូស្លូវ៉ាគី សាធារណរដ្ឋហុងគ្រី និង ហ្សាម៉ាហ៊ីរីយ៉ាអារ៉ាប់លីប៊ី ប្រជាមានិតសង្គមនិយម ។

*មាត្រា ២.* — ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ ១៩៩០*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា :

ហេង សំរិន

Downloaded from http://www.khmerlaws.com

# II – ក្រុមប្រឹក្សារដ្ឋមន្ត្រី

## *១ – អនុក្រឹត្យ*

*ភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩០*

## អនុក្រឹត្យលេខ ០២ អន-ក្រ

## ស្តីពីអនាម័យ ចំណីអាហារ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញសេចក្តីសំរេចកំណត់លេខ ៨៣-៨០ កច ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៨០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ស្តីពីតួនាទីភារកិច្ច និង អង្គការចាត់តាំងក្រសួងសុខាភិបាល

— បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ញា

— តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

## សំរេច

## ជំពូកទី ១

### *បទបញ្ញត្តិទូទៅ*

*មាត្រា ១* — អនាម័យចំណីអាហារ គឺជាវិធីសាស្ត្រនិងការគ្រប់គ្រងការ ធ្វើអោយចំណីអាហារបានស្អាតបរិសុទ្ធ រក្សាគុណភាពអនាម័យ ដើម្បីធានាទូវអនាម័យក្នុងការបរិភោគ ។

*មាត្រា ២* — ដើម្បីធានាសុខភាពដល់អ្នកបរិភោគចំណីអាហារ ត្រូវតែមានការត្រួតពិនិត្យ ។ ចំណីអាហារដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យមាន :

ក — ចំណីអាហារឆ្អិនស្រេច ឬ មិនបាច់ចំអិន អាចបរិភោគបានដូចជា : នំ បន្លែ ផ្លែឈើ ទឹកស៊ីអ៊ីវ សៀងទឹកត្រី ទឹកក្រូច ស្រា ស្រាបៀរ សូដា ។

Downloaded from http://www.khmerlaws.com

ខ — ចំណីអាហារនៅឆៅយកទៅផ្សំ ឬ ចំអិន ទើបអាចបរិភោគបានមាន ៖ សាច់-ជ្រូក គោ មាន់ ទា ត្រី និង សាច់សត្វផ្សេងៗ ទៀត ។

គ — ចំណីអាហារដាក់កំប៉ុង កែវ ថង់ ស្បោងប្លាស្ទិច ក្រឡ ឬ ប្រអប់ផ្សេងៗ ។

## ជំពូកទី ២

### *ភារកិច្ច និង សិទ្ធិម្ចាស់ចំណីអាហារ*

*មាត្រា ៣* .— មូលដ្ឋានផលិតកន្លែងស្តុក កន្លែងចែកចាយចំណីអាហារ ភោជនីយដ្ឋាន ត្រូវមានទីតាំងសមស្របតាមលក្ខណៈអនាម័យ ។

*មាត្រា ៤* .— មូលដ្ឋានផលិត កន្លែងស្តុក កន្លែងចែកចាយចំណីអាហារ ភោជនីយ-ដ្ឋានមានលក្ខណៈងាយស្រួលដល់ក្រុមភ្នាក់ងារអនាម័យក្នុងការត្រួតពិនិត្យ ។

*មាត្រា ៥* .— អ្នកផលិតចែកចាយ វេចខ្ចប់ចំណីអាហារ អ្នកបំរើក្នុងភោជនីយដ្ឋាន ត្រូវពិនិត្យសុខភាពយ៉ាងតិច ឆ្នាំមួយខែម្តង ។

*មាត្រា ៦* .— មូលដ្ឋានផលិត ម្ចាស់ចំណីអាហារ មានសិទ្ធិប្តឹងតវ៉ាពីក្រុមភ្នាក់ងារអនាម័យក្នុងករណីដែលមានការរំលោភច្បាប់ ឬ មិនសុខចិត្តពីលទ្ធផលវិភាគ ឬគោលល្បើចំណីអាហារ ។

## ជំពូកទី ៣

### *អំពីសិទ្ធិ និងសមត្ថកិច្ចត្រួតពិនិត្យចំណីអាហារ*

*មាត្រា ៧* . នៅមជ្ឈិម ការត្រួតពិនិត្យចំណីអាហារ ជាសមត្ថកិច្ចរបស់ក្រុមភ្នាក់ងារអនាម័យចំណីអាហារ នៃក្រសួងសុខាភិបាល ។

នៅខេត្ត - ក្រុង ការត្រួតពិនិត្យចំណីអាហារ ជាសមត្ថកិច្ចរបស់ក្រុមភ្នាក់ងារអនាម័យចំណី-អាហារដែលតែងតាំងឡើងដោយគណៈកម្មាធិការប្រជាជន ខេត្ត-ក្រុង តាមសំណើរបស់មន្ទីរសុខាភិបាលខេត្ត - ក្រុង ។

*មាត្រា ៨* .— ក្រុមភ្នាក់ងារអនាម័យចំណីអាហារមានសិទ្ធិដូចតទៅ ៖

ក — ត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ អនុក្រឹត្យ សារាចរ សេចក្តីសំរេច បទបញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធនឹងអនាម័យចំណីអាហារ ។

ខ — ហាមឃាត់ការផលិត ការលក់ ការចែកចាយចំណីអាហារ ដែលមានគុណភាពមិនសមស្របតាមក្បួនអនាម័យ ។

Downloaded from http://www.khmerlaws.com

គ — ចេញចូលក្នុងមូលដ្ឋានផលិត ចែកចាយចំណីអាហារ ភោជនីយដ្ឋាន ដើម្បីពិនិត្យស្ថានភាពអនាម័យ ។

ឃ — ស្រង់យកគំរូចំណីអាហារសំរាប់ធ្វើការវិភាគក្នុងករណីមានការសង្ស័យថា ខ្វះគុណភាពអនាម័យ ។

ង — ចេញលិខិតបញ្ជាក់អនាម័យចំណីអាហារអោយម្ចាស់ទំនិញ ឬ តំណាង ។

ច — ព្រមាន ឬ ពិន័យជាប្រាក់ ។

ឆ — ធ្វើកំណត់ហេតុអំពីការត្រួតពិនិត្យ ក្នុងករណីមានបទល្មើស ។

ជ — ឃាត់ទុក ឬ បង្ខូចចោលនូវចំណីអាហារដែលខ្វះគុណភាពអនាម័យ ។ ក្នុងករណីមានការតវ៉ាពីការឃាត់ទុក ការបង្ខូចចោល ឬ តវ៉ាអំពីប្រាក់ពិន័យ នោះត្រូវក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលខេត្ត - ក្រុង ជាអ្នកពិនិត្យ និង សំរេច ។ ប្រសិនបើមិនព្រម បង់ប្រាក់ពិន័យ នោះត្រូវបញ្ជូនសំណុំរឿង ព្រមទាំងវត្ថុតាងទៅតុលាការ ដើម្បីសំរេច ។

*មាត្រា ៩ .—* ក្រសួងសុខាភិបាល មានភារកិច្ចការពារសុខភាពប្រជាជន ការពារផ្តាច់ការចម្លងរោគនិងគ្រោះថ្នាក់បណ្តាលមកពីចំណីអាហារ ព្រមទាំងសហការជាមួយក្រសួងពាក់ព័ន្ធ ធ្វើសេចក្តីណែនាំកំណត់បែបបទ លក្ខណៈបច្ចេកទេសនៃការពិនិត្យចំណីអាហារ ដើម្បីធានានូវគុណភាពអនាម័យ នៃចំណីអាហារ ។

*មាត្រា ១០ .—* ក្នុងពេលបំពេញភារកិច្ច ភ្នាក់ងារអនាម័យចំណីអាហារ ត្រូវស្លៀកពាក់ឯកសណ្ឋានពាក់សញ្ញាសំគាល់ មានលិខិតសំគាល់ខ្លួន និង លិខិតបញ្ជាបេសកកម្មជាប់នឹងខ្លួន ។

*មាត្រា ១១ .—* រដ្ឋអំណាចមូលដ្ឋាន ត្រូវជួយសហការជាមួយក្រុមភ្នាក់ងារអនាម័យចំណីអាហារ បើមានការស្នើសុំ ។

## ជំពូកទី ៤

### *ទោសប្បញ្ញត្តិ*

*មាត្រា ១២ .—* ក្នុងករណីប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ ត្រូវព្រមានបង្ខូចចោល ឬ ពិន័យជាប្រាក់ ប្រាក់ពិន័យត្រូវបានជាប្រយោជន៍ នៃថវិកាជាតិ ។

*មាត្រា ១៣ .—* ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៣.៤.៥ និងមាត្រា ៨ ចំណុច « ខ »

Downloaded from http://www.khmerlaws.com

នៃអនុក្រឹត្យនេះ ត្រូវព្រមាន ឬ ពិន័យជាប្រាក់ពី ២០ រៀល ទៅ ២០០ រៀល ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេមុខៈជាពីរ ។

*មាត្រា ១៤* – ភ្នាក់ងារអនាម័យចំណីអាហារ អ្នកវិភាគ ឬ អ្នកធ្វើកោសល្យវិច័យ ខ្វះស្មារតីទទួលខុសត្រូវក្នុងភារកិច្ច បណ្តាលអោយខូចប្រយោជន៍ដល់ម្ចាស់ចំណីអាហារ ត្រូវផ្តន្ទាទោសតាមច្បាប់ រដ្ឋបាលដូចជាព្រមាន ស្តីបន្ទោស បញ្ចុះថ្នាក់ ឬ បានៈអោយលាឈប់ពីការងារដោយបង្ខំ ឬ បណ្តេញចេញមិនគិតដល់សំណង់ នៃការខូចខាតដែលបណ្តាលមកពីអំពើប្រព្រឹត្តរបស់ខ្លួន ។

– ជនណារំលោភលើមុខងារអំណាចរបស់ខ្លួន បណ្តាលអោយខូចទ្រព្យសម្បត្តិរបស់រដ្ឋ ទ្រព្យសម្បត្តិចំរុះរដ្ឋ និង ឯកជន សមូហភាពឯកជន ឬ ប្រព្រឹត្តបទសំណូក ក្នុងការងារត្រួតពិនិត្យអនាម័យចំណីអាហារត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៥

### *អវសានបញ្ញត្តិ*

*មាត្រា ១៥* – បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍

*មាត្រា ១៦* – ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងសុខាភិបាល ស្ថាប័ន ក្រសួងពាក់ព័ន្ធ និង គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

*មាត្រា ១៧* – អនុក្រឹត្យនេះ មានអនុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ចាន់ ស៊ី

Downloaded from http://www.khmerlaws.com

## ២ - សេចក្តីសំរេច

*ភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩០*

## សេចក្តីសំរេច លេខ ០៥ សសរ
## ស្តីពី ថ្លៃលក់ជីគីមីគ្រប់ប្រភេទ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម

## សំរេច

*ប្រការ ១* : កំណត់ថ្លៃលក់ជីគីមីគ្រប់ប្រភេទ ឯកភាពទូទាំងប្រទេសជាសាច់ប្រាក់ដូចក្នុងតារាងខាងក្រោមនេះ -

| | |
|---|---|
| ១ - ជីអ៊ុយរ៉េ ៤៦ ភាគរយអាសូត | ថ្លៃ ១៩៛០០ ក្នុង ១ គ.ក្រ. |
| ២ - ជីតាម៉ូហ្វូស | ថ្លៃ ២៣៛៥០ ក្នុង ១ គ.ក្រ. |
| ៣ - ជី ១៦.២០.០ | ថ្លៃ ២១៛២៥ ក្នុង ១ គ.ក្រ. |
| ៤ - ជី ១៥.១៥.១៥ | ថ្លៃ ១៩៛០០ ក្នុង ១ គ.ក្រ. |
| ៥ - ជី ១៦.២០.៣ | ថ្លៃ ២១៛២៥ ក្នុង ១ គ.ក្រ. |
| ៦ - ជី ១៦.២០ | ថ្លៃ ១៨៛៥០ ក្នុង ១ គ.ក្រ. |
| ៧ - ជី ១៨.៤៦.០ | ថ្លៃ ២៣៛៥០ ក្នុង ១ គ.ក្រ. |
| ៨ - ជីស៊ុលហ្វាតអាម៉ូញ៉ូម ២៤ ភាគរយ | ថ្លៃ ១៨៛៥០ ក្នុង ១ គ.ក្រ. |
| ៩ - ជីស៊ុបពែហ្វូសហ្វាត | ថ្លៃ ១៨៛៥០ ក្នុង ១ គ.ក្រ. |
| ១០ - ក្លរ៉ូជីប៉ូតាស្យូម | ថ្លៃ ១៨៛៥០ ក្នុង ១ គ.ក្រ. |
| ១១ - ស៊ុលហ្វាតជីប៉ូតាស្យូម | ថ្លៃ ១៨៛៥០ ក្នុង ១ គ.ក្រ. |

*ប្រការ ២* : ចំពោះជីគីមីផ្សេងៗទៀតដែលពុំមានចែងក្នុងប្រការ ១ ខាងលើ ក្រុមប្រឹក្សា

Downloaded from http://www.khmerlaws.com

រដ្ឋមន្ត្រីប្រគល់ភារកិច្ចជូនក្រសួងកសិកម្មពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ ដើម្បីកំណត់ថ្លៃលក់តាមសភាពជាក់ស្តែង ។

*ប្រការ ៣* : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ ក្រសួងកសិកម្ម ធនាគារជាតិនៃប្រជាជនកម្ពុជា និងគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត - ក្រុង មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

– បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ផ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ចា សុទ

*ភ្នំពេញ, ថ្ងៃទី ១២ ខែមករា ឆ្នាំ ១៩៩០*

# សេចក្តីសំរេចលេខ ០៨ សសរ

## ស្តីពីការបង្កើតរុក្ខទិវា

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញក្រឹត្យ- ច្បាប់លេខ ៣៥ ក្រច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ

– តាមសំណើរបស់សមមិត្តរដ្ឋមន្ត្រីក្រសួងកសិកម្ម

Downloaded from http://www.khmerlaws.com

# សំរេច

*ប្រការ ១ :* បង្កើតទិវាពលកម្មដាំដើមឈើ ហៅថា រុក្ខទិវា ដែលត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី ០៩ ខែ កក្កដា ជារៀងរាល់ឆ្នាំ ។

*ប្រការ ២ :* ទិសដៅរុក្ខទិវាគឺជំរុញការអប់រំប្រជាពលរដ្ឋអោយយល់ពីសារៈសំខាន់ និង ផលប្រយោជន៍ព្រៃឈើ និង បំផុសរុក្ខទិវាអោយក្លាយទៅជាបុណ្យជាតិ ដែលពលរដ្ឋគ្រប់រូបត្រូវមានភារកិច្ចប្រារព្ធអោយបានទៀងទាត់ ។

*ប្រការ ៣ :* ពិធីដាំដើមឈើនេះប្រព្រឹត្តឡើងពេញ ១ ថ្ងៃ នៅក្នុងបរិវេណដែលត្រូវដាំដើមឈើឡើងវិញ ។

*ប្រការ ៤ :* គណៈកម្មាធិការប្រជាជនខេត្ត- ក្រុង មានភារកិច្ចរៀបចំចាត់តាំងពិធីបុណ្យរុក្ខទិវានេះអោយបានជាប្រចាំ ដោយម្ចាស់ការចាប់ពីការងារថ្នាលរពេតដល់ការងារដាំដុះ ។

*ប្រការ ៥ :* គណៈកម្មាធិការប្រជាជនខេត្ត- ក្រុង ត្រូវមានវិធានការការពារ ថែទាំអោយបានគង់វង្សក្រោយពីការដាំរួច ។

*ប្រការ ៦ :* ក្រសួងកសិកម្មមានភារកិច្ចណែនាំបច្ចេកទេស និង ត្រួតពិនិត្យការអនុវត្ត ។

*ប្រការ ៧ :* បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍។

*ប្រការ ៨ :* ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន និង គណៈកម្មាធិការប្រជាជន ខេត្ត - ក្រុង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង ។ ខ្លួនអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

Downloaded from http://www.khmerlaws.com

*ភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ ១៩៩០*

# សេចក្ដីសំរេច លេខ ១៧ សសរ

## ស្ដីពីការបង្កើតគណៈកម្មការត្រួតពិនិត្យការគ្រប់គ្រងសាច់ប្រាក់ របស់មូលដ្ឋានខេត្ត–ក្រុង

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្ដីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- ពិនិត្យសំណូមពរ និង ការងារចាំបាច់

## សំរេច

*ប្រការ ១* : បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - សមមិត្ត រដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ | ប្រធាន |
| - សមមិត្ត អនុរដ្ឋមន្ត្រី ក្រសួងត្រួតពិនិត្យ | អនុប្រធាន |
| - សមមិត្ត អនុរដ្ឋមន្ត្រី ក្រសួងផែនការ | សមាជិក |
| - សមមិត្ត អនុរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | សមាជិក |
| - សមមិត្ត អនុប្រធាន ធនាគារជាតិកម្ពុជា | សមាជិក |
| - ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី | សមាជិករាយការណ៍ |

*ប្រការ ២* : គណៈកម្មការនេះ មានភារកិច្ចចុះតាមបណ្ដាខេត្ត - ក្រុង សំខាន់ៗ ដើម្បី ៖

- ត្រួតពិនិត្យការគ្រប់គ្រង ការប្រើប្រាស់ និង ការប្រមូលសាច់ប្រាក់របស់មូលដ្ឋាន ។
- ពិនិត្យតម្រូវការសាច់ប្រាក់ - សំរាប់ចំណាយរបស់មូលដ្ឋាននីមួយ ៗ ពិសេសសាច់ប្រាក់សំរាប់បំរើការងារប្រមូលទិញស្បៀង និង កសិផលសំខាន់ ៗ ។
- ពិនិត្យ និង ដោះស្រាយបំណុលរ៉ាំរ៉ៃទាំងឡាយរបស់បណ្ដាអង្គភាព ។

*ប្រការ ៣*: សមាសភាពនេះអាចបន្ថែមបានតម្រូវការងារជាក់ស្ដែង ដែលប្រធានគណៈកម្មការសំរេចឃើញថាចាំបាច់ ។

*ប្រការ ៤* : គណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សមមិត្តប្រធាន

Downloaded from http://www.khmerlaws.com

ហើយត្រូវរាយការណ៍ប្រចាំខែជូនក្រុមប្រឹក្សារដ្ឋមន្ត្រី អំពីលទ្ធផលនៃសកម្មភាពការងារដែលសំរេចបាននៅមូលដ្ឋាននីមួយ ៗ ។

គណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សមមិត្តប្រធាន ហើយត្រូវរាយការណ៍ជាប្រចាំខែជូនក្រុមប្រឹក្សារដ្ឋមន្ត្រី អំពីលទ្ធផលនៃសកម្មភាពការងារដែលសំរេចបាននៅមូល-ដ្ឋាននីមួយ ៗ ។

គណៈកម្មការត្រូវបានប្រើប្រាស់ត្រារបស់ក្រសួងហិរញ្ញវត្ថុ ដើម្បីសំរួលការងាររបស់ខ្លួន ។

*ប្រការ ៥* : គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង ព្រមទាំងផ្នែកជំនាញត្រូវបង្កគ្រប់លក្ខណៈងាយស្រួលដល់គណៈកម្មការនេះ ដើម្បីសំរេចភារកិច្ចរបស់ខ្លួនបានល្អ ត្រឹមត្រូវឆាប់រហ័ស រួមចំណែកយ៉ាងសំខាន់ និង ទាន់ពេលវេលា ដោះស្រាយបាន សំណូមពរសាច់ប្រាក់នៃថវិការដ្ឋដែលកំពុងជួបការលំបាក ។

*ប្រការ ៦* : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ ក្រសួងត្រួតពិនិត្យ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃប្រជាជនកម្ពុជា គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង និង សាមីខ្លួន ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ចា សុទ

Downloaded from http://www.khmerlaws.com

## ឃ – សារាចរ

ភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ១៩៩០

## សារាចរ លេខ ០១ សរ

## ស្តីពីការគ្រប់គ្រងគេហដ្ឋាន ដីធ្លីដែលផ្តល់អោយអង្គការ អន្តរជាតិ – ក្រុមហ៊ុន ឬជនបរទេស

ក្នុងទិសពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយបណ្តាប្រទេសសង្គមនិយមជាបងប្អូន និងអង្គការអន្តរជាតិនានា ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ច អោយបានប្រសិទ្ធភាព និងបង្កលក្ខណៈឡាក់អោយក្រុមហ៊ុន ឬ ភ្ញៀវបរទេសចូលមកធ្វើអាជីវកម្ម ផលិតកម្ម ដើម្បីរួមចំណែកស្តារសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេសជាតិ បញ្ហាដោះស្រាយគេហដ្ឋាន ដីធ្លី សំរាប់បណ្តាអង្គការអន្តរជាតិក្រុមហ៊ុន ឬ ភ្ញៀវបរទេសនៅទីក្រុងភ្នំពេញ និង តាមទីរួមខេត្តនានា គឺជាការចាំបាច់សំខាន់មួយផ្នែកដែរ ។

ផ្អែកតាមសភាពការណ៍នេះ ក្រុមប្រឹក្សារដ្ឋមន្ត្រី កំណត់នូវវិធានការចាំបាច់ចំពោះមុខដូចខាងក្រោមនេះ ៖

១ – ជនបរទេសដែលបានទទួលការអនុញ្ញាតអោយស្នាក់នៅក្នុងរដ្ឋកម្ពុជា មានសិទ្ធិជួលគេហដ្ឋានដីធ្លីបាន ។

២ – ក្រសួងការបរទេស ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ត្រូវរួមគ្នាទទួលខុសត្រូវក្នុងការរៀបចំគេហដ្ឋានដីធ្លីដល់បណ្តាអង្គការអន្តរជាតិ ក្រុមហ៊ុន ឬ ភ្ញៀវបរទេសដែលធ្វើសកម្មភាពនៅតាមខេត្ត - ក្រុងនិមួយៗ ដោយត្រូវយកចិត្តទុកដាក់សំខាន់បំផុតដល់បញ្ហាថែរក្សាការពារសន្តិសុខជូនភ្ញៀវអោយបានល្អ ។

៣ – អនុញ្ញាតអោយពលរដ្ឋកម្ពុជា អាចជួលគេហដ្ឋានដីធ្លីជាកម្មសិទ្ធិរបស់ខ្លួនដល់អង្គការអន្តរជាតិក្រុមហ៊ុន ឬ ភ្ញៀវបរទេសណាដែលមានការអនុញ្ញាតអោយស្នាក់អាស្រ័យនៅ និងធ្វើរបសកម្មនៅក្នុងរដ្ឋកម្ពុជាពីក្រសួងការបរទេស ។ ការជួលគេហដ្ឋានដីធ្លីនេះ ត្រូវមានការអនុញ្ញាតពីគណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ដោយមានយោបល់ឯកភាពពីក្រសួងមហាផ្ទៃ និងក្រសួងការបរទេស ។ ពលរដ្ឋកម្ពុជាដែលមានគេហដ្ឋាន ដីធ្លីជាកម្មសិទ្ធិហើយមានបំណងចង់ជួលអោយជនបរទេសចាំបាច់ត្រូវមកចុះឈ្មោះផ្តល់ពត៌មានដល់គណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ។

Downloaded from http://www.khmerlaws.com

៤ – ក្នុងការកំណត់ថ្លៃ ឈ្នួលគេហដ្ឋានដីធ្លីជាមូលដ្ឋានសំរាប់ជនបរទេស គណៈកម្មាធិការប្រជាជនខេត្ត - ក្រុង រៀបចំបទដ្ឋានមួយនៅតាមភូមិសាស្ត្រ និង ប្រភេទគេហដ្ឋានដីធ្លីនីមួយៗ ។ ផ្អែកតាមថ្លៃឈ្នួលជាមូលដ្ឋាននេះ ម្ចាស់គេហដ្ឋានដីធ្លីនឹងពិភាក្សាលំអិតដាក់ស្តែងថែមទៀតអោយឯកភាពជាមួយអ្នកទទួលជួល ។

៥ – ម្ចាស់កម្មសិទ្ធិគេហដ្ឋានដីធ្លីដែលជួលអោយជនបរទេសត្រូវមានភារកិច្ចដូចតទៅ ៖

– ចូលរួមក្នុងចលនាការពារសន្តិសុខសណ្តាប់ធ្នាប់សង្គម ។

– ត្រូវបង់ពន្ធប៉ាតង់ និង ពន្ធអាជីវកម្មចំពោះចំណូលដែលបានមកពីការជួលគេហដ្ឋាន ដីធ្លីតាមបណ្តាក្រឹត្យ - ច្បាប់ដែលមានថែង ។

- ត្រូវបើកគណនី ជាប្រាក់រៀលនៅធនាគារ ហើយត្រូវផ្ទេរថ្លៃឈ្នួលគេហដ្ឋាន ដីធ្លីពីរូបិយប័ណ្ណបរទេសមកជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ដែលប្រកាសផ្សាយ ដោយធនាគារជាតិកម្ពុជាបញ្ចូលទៅក្នុងគណនីខាងលើ ។

- កិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ ជួលគេហដ្ឋានដីធ្លី អោយជនបរទេស ត្រូវបានការឯកភាពពីគណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ។

៦ - អ្នកជួលគេហដ្ឋាន ដីធ្លី មានភារកិច្ចគោរពតាមកិច្ចសន្យាដែលបានឯកភាពចុះហត្ថលេខាជាមួយម្ចាស់គេហដ្ឋានដីធ្លី ។

គ្រប់ក្រសួង, ស្ថាប័ន គណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ផ្អែកលើខ្លឹមសារនៃសារាចរនេះ ត្រូវធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយ និងចាត់តាំងអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

Downloaded from http://www.khmerlaws.com

*ភ្នំពេញ ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩០*

# សារាចរលេខ ០២ សរ

## ស្តីពីការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម នៅតាមបណ្តាខេត្ត-ក្រុង ក្នុងទូទាំងប្រទេស

ចាប់ពីក្រោយថ្ងៃរំដោះរហូតមកដល់បច្ចុប្បន្ន កិច្ចការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមមានការរីកចំរើនរួមចំណែកខ្លាំងក្លាដល់ភារងារកសាងការពារប្រទេសជាតិ ការពារសមិទ្ធផលបដិវត្ត ប្រជាជន មហាជនកាន់តែមានជំនឿជឿជាក់រឹងមាំចំពោះរបបថ្មីនៃយើង ។

ទោះបីជាយ៉ាងដូច្នេះក៏ដោយ យើងក៏ពិនិត្យឃើញនៅមានចំណុចខ្វះខាតមួយចំនួនជុំវិញការងារនេះ សំខាន់គឺមិនទាន់ក្លាយទៅជាចលនាភ្ញាក់រលឹកខ្ពស់ព្រមៗ គ្នារបស់ប្រជាជន មហាជននៅឡើយ ការដោះស្រាយបណ្តាបញ្ហាជាប្រភពឫសគល់ និងការឃើញបណ្តាករណីល្មើសច្បាប់នៅយឺតយ៉ាវ បញ្ហាស្មុគ្រស្មាញមួយចំនួន ដូចជាការលួច ឆក់ ប្លន់ សម្លាប់មនុស្ស ការប្រើអាវុធជាតិផ្ទុះខុសច្បាប់ គ្រោះថ្នាក់ចរាចរ គ្រោះថ្នាក់អគ្គីភ័យ ការបាត់សណ្តាប់ធ្នាប់ អនាម័យសាធារណៈ ការផ្សព្វផ្សាយវប្បធម៌កាលាអាវ៉ាសែ ល្បែងស៊ីសង ស្រីពេស្យា ប្រើគ្រឿងស្រវឹង គ្រឿងញៀន . . . ។ល។ នៅពុំទាន់មានអន់ថយ និងកំពុងជះឥទ្ធិពលដល់សតិអារម្មណ៍ ជីវភាពរស់នៅរបស់ប្រជាជន មហាជន ពិសេសនៅរដ្ឋធានីភ្នំពេញ ។ ឯខ្មាំងសត្រូវកំពុងផ្សងព្រេងរំពឹះខាងផ្លូវនយោបាយ ពួកវាក៏ឆ្លៀតឱកាសប្រើក្រប៉ីកលល្បិចធ្វើអោយបាត់សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ដើម្បីបង្កប្រៀបថ្មីជាមួយបដិវត្តយើង ។

ចំពោះយើង បច្ចុប្បន្នយើងកំពុងអនុវត្តនូវភាពម្ចាស់ការស្វ័យរ៉ាប់រងដោយខ្លួនឯងលើជោគវាសនាប្រទេសជាតិដែលដាច់ខាតត្រូវតែធានាអោយបាននូវសមិទ្ធផលបដិវត្តរបស់ប្រជាជនយើង ។ ចំពោះមុខសភាពការណ៍នេះ កិច្ចការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម គឺជាភារកិច្ចសំខាន់ បន្ទាន់របស់បក្សទាំងមូល កងកម្លាំងប្រដាប់អាវុធទាំងមូល និងប្រជាជនទាំងមូល ។ ដើម្បីសំរេចសំណូមពរនេះ ក្រុមប្រឹក្សារដ្ឋមន្ត្រីសូមធ្វើការណែនាំដូចខាងក្រោម ៖

១ - ត្រូវបំផុសផ្សព្វផ្សាយដល់កម្មាភិបាល យុទ្ធជន បុគ្គលិក កម្មករ មហាជន ប្រជាជនអោយបានទូលំទូលាយ និងយល់ច្បាស់អំពីផលប្រយោជន៍នៃការអនុវត្តន៍ច្បាប់ និង គ្រោះថ្នាក់នៃបទល្មើសច្បាប់រដ្ឋ ព្រមទាំងលើកកំពស់ស្មារតីភ្ញាក់រលឹកសកម្មចូលរួមក្នុងចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គមអោយបានផុលផុស ក្លាយទៅជាចលនាមួយជាគន្លឹះក្នុងការកសាង ការពារ

Downloaded from http://www.khmerlaws.com

ប្រទេសជាតិយើង ។ ត្រូវដាក់ចេញបណ្ដាខ្លឹមសារខ្លី ៗ បំផុសអោយមហាជន ប្រជាជនប្រឡងប្រណាំងអនុវត្តដោយមានការសរសើរលើកទឹកចិត្តជនរង្វាន់ចំពោះបុគ្គល និង អង្គភាពដែលអនុវត្តបានល្អ មានស្នាដៃ ព្រមទាំងយកចិត្តទុកដាក់អប់រំរៀនសូត្រអោយប្រជាជន មហាជនជ្រួតជ្រាបរាល់បណ្ដាក្រឹត្យ - ច្បាប់ សារាចរ បទកំណត់ផ្សេង ៗ របស់បក្ស និង រដ្ឋ ។

២- ត្រូវមានវិធានការដោះស្រាយបណ្ដាបញ្ហាជា ប្រភពឫសគល់ដែលនាំអោយកើតនូវករណីល្មើសច្បាប់

៣- ត្រូវប្រើប្រាស់នូវរាល់វិធានការចុះជំនាញ វិធានការច្បាប់ និង វិធានការរដ្ឋបាល ដើម្បីព្រមាន និង ផ្ដន្ទាទោសទាន់ពេលចំពោះជនប្រព្រឹត្តល្មើសច្បាប់ ពិសេសពួកជនទមក្មេង ។ ត្រូវពិចារណាកែសំរួល និង កសាងបន្ថែមបណ្ដាច្បាប់ និង បទកំណត់ផ្សេងៗរបស់រដ្ឋ ដើម្បីអោយសមស្របចំពោះសភាពការណ៍ថ្មីរបស់បដិវត្ត ។

ដើម្បីអនុវត្តវិធានការខាងលើ គ្រប់ស្ថាប័ន ក្រសួង មន្ទីរដែលមានការពាក់ព័ន្ធនិងខេត្ត-ក្រុងពិសេសរដ្ឋធានីភ្នំពេញ ត្រូវយកចិត្តទុកដាក់អនុវត្តចំណុចដូចខាងក្រោមនេះ :

ក- ក្រសួងមហាផ្ទៃ : ត្រូវមានផែនការណែនាំ ត្រួតពិនិត្យជាបន្ទាន់ដល់កងកម្លាំងនគរបាលគ្រប់ថ្នាក់ អនុវត្តនូវរាល់ការងារមួយចំនួន ដូចជា : ការងារគ្រប់គ្រងស្ថិតិ ការគ្រប់គ្រងអាវុធជាតិផ្ទុះ ការងារបង្ការរាំងស្កាត់ និង គស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ សេដ្ឋកិច្ច ការអនុវត្តច្បាប់ចរាចរការរក្សាសណ្ដាប់ធ្នាប់សាធារណៈ ការបង្ការ ពន្លត់អគ្គិភ័យ និងការបង្ការចលាចល សន្តិសុខ។ល។

ខ- ក្រសួងការពារប្រទេស ត្រូវបង្កើនការអប់រំ ពង្រឹងការអនុវត្តវិន័យ និង សីលធម៌របស់កងទ័ពអោយបានហ្មឹងម៉ាត់ចំពោះកម្មាភិបាល យុទ្ធជនគ្រប់ថ្នាក់ ។

ក្រសួងការពារប្រទេស និង ក្រសួងមហាផ្ទៃត្រូវផ្សព្វផ្សាយរៀនសូត្រជាប្រចាំអោយដល់កម្មាភិបាល យុទ្ធជនគ្រប់ថ្នាក់អោយយល់ជ្រួតជ្រាបអំពីច្បាប់របស់រដ្ឋ និង ត្រូវពង្រឹងស្មារតីទទួលខុសត្រូវក្នុងការគ្រប់គ្រងអាវុធ ជាតិផ្ទុះ ដើម្បីរាំងស្កាត់អោយបាននូវបាតុភាពយុទ្ធជនរត់ចោលជួរហើយនាំយកអាវុធគ្រាប់រំសេវទៅជាមួយ ។ ត្រូវសហការជាមួយក្រសួង ស្ថាប័ន និង រដ្ឋអំណាចគ្រប់ជាន់ថ្នាក់ អនុវត្តអោយបានហ្មឹងម៉ាត់នូវសារាចរ លេខ ១១ ស.រ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីការគ្រប់គ្រងបែងចែក និង ការកំណត់សិទ្ធិប្រើប្រាស់អាវុធ ។

គ- ក្រសួងឃោសនាការ វប្បធម៌ សហការជាមួយក្រសួងមហាផ្ទៃ និង ខេត្ត-ក្រុងអនុវត្ត

Downloaded from http://www.khmerlaws.com

អនុក្រឹត្យលេខ ៣២ អនក្រ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការគ្រប់គ្រងត្រួតពិនិត្យភាពយន្ត និង វីដេអូ ទៅតាមតួនាទីភារកិច្ចរបស់ខ្លួនអោយបានហ្មត់ចត់ ។

ឃ- ក្រសួងយុទ្ធជនពិការ និង សង្គមកិច្ច ត្រូវមានវិធានការអប់រំស្រីពេស្យា ជនអនាថា ពួកប្រព្រឹត្តគ្រឿងញៀន ដើម្បីកែប្រែគេ បណ្តុះបណ្តាល បង្កលក្ខណៈអោយគេមានមុខជំនាញវិជ្ជាជីវៈ ក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម ។

ង- ក្រសួងសុខាភិបាល ត្រូវសហការផ្តល់គ្រូពេទ្យឯកទេសជំនាញ ចូលរួមព្យាបាលដល់ពួកមុខសញ្ញាខាងលើ ។

ច- បណ្តាស្ថាប័នឃោសនាអប់រំ និង អង្គការមហាជនគ្រប់ថ្នាក់ ត្រូវមានកម្មវិធីបំផុសប្រជាជនមហាជនអោយចូលរួមក្នុងភារកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម ។ ក្រសួងអប់រំត្រូវបញ្ចូលខ្លឹមសារនេះនៅក្នុងកម្មវិធីសិក្សា សំដៅអោយសិស្សានុសិស្សយល់ជ្រួតជ្រាប និង រាំងស្កាត់បានទាន់ពេលវេលា មិនទុកអោយពួកខ្មាំង និងពួកប្រព្រឹត្តបទល្មើស ឆ្លៀតឱកាសអូសទាញយុវជន សិស្សានុសិស្សអោយបំរើឧបាយកលរបស់ពួកវា ។

លើមូលដ្ឋាននៃច្បាប់របស់រដ្ឋដែលមានជាធរមាន គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ផ្អែកតាមតួនាទីភារកិច្ចរបស់ខ្លួន ត្រូវធ្វើការណែនាំដល់ខ្សែរយៈរបស់ខ្លួននៅមូលដ្ឋានដើម្បីសកម្មភាពចូលរួមអនុវត្តស្មារតីសារាចរនេះអោយមានប្រសិទ្ធភាព ដោយឡែករដ្ឋធានីភ្នំពេញដែលជាមជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌សង្គម និង ប្រមូលផ្តុំភ្ញៀវអន្តរជាតិ ត្រូវមានផែនការជាបន្ទាន់ និង ជាប្រចាំនូវការត្រួតពិនិត្យសណ្តាប់ធ្នាប់ អនាម័យសាធារណៈទាំងពេលថ្ងៃ និង ពេលយប់ ដើម្បីទប់ទល់សមាសភាពអាក្រក់ប៉ុនប៉ងបំផ្លិចបំផ្លាញសណ្តាប់ធ្នាប់ និង សមិទ្ធផលសង្គមជាតិ ។

ទទួលបានសារាចរនេះ សំណូមពរគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវមានផែនការណែនាំលំអិតតាមមុខជំនាញ និង ភារកិច្ចរបស់ខ្លួន ។ គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង មានភារកិច្ចចាត់តាំងអនុវត្តផ្ទាល់ រួចរាយការណ៍អំពីលទ្ធផលដែលសំរេចបានមកក្រុមប្រឹក្សារដ្ឋមន្ត្រី ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ជា សុន

Downloaded from http://www.khmerlaws.com

# III- ការងារបណ្តាក្រសួង

## ក្រសួងឃោសនាការ និងវប្បធម៌

### សេចក្តីជូនដំណឹង

*ភ្នំពេញ, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩០*

### សេចក្តីជូនដំណឹងលេខ ០១ សជណ

អំពីការអនុវត្តគោលការណ៍ធ្វើអាជីវកម្មនាំចេញ
នាំចូល និង ចែកបញ្ចាំងភាពយន្ត និង វីដេអូ

ដោយអនុវត្តតាមអនុក្រឹត្យ លេខ ៣២ អ.ន.ក្រ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៩ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យភាពយន្ត និង វីដេអូ និងសារាចរណែនាំអនុវត្តរបស់ក្រសួងឃោសនាការ និងវប្បធម៌ លេខ ០៥ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៨៩ និងក្នុងបំណងអនុវត្តអោយបានសុក្រឹត្យក្នុងការគ្រប់គ្រងអាជីវកម្មនាំចេញ នាំចូល និង ចែកបញ្ចាំងភាពយន្ត និង វីដេអូកាសែត ជាពិសេសដើម្បីទប់ស្កាត់ការនាំចូលភាពយន្ត និង វីដេអូកាសែតតាមមធ្យោបាយគេចពន្ធ មធ្យោបាយដោយលួចលាក់បែបណាមួយនោះ ម្យ៉ាងទៀតដោយសង្កេតឃើញថាកន្លងមកមានបុគ្គលមួយចំនួនបានធ្វើអាជីវកម្មនាំចូលភាពយន្ត ឬ វីដេអូកាសែត ជាលក្ខណៈគេចពន្ធ ហើយបានបែងចែកទៅអោយបណ្តាក្រុមហ៊ុនចែកបញ្ចាំង ឬ ទៅអោយបុគ្គលដែលធ្វើអាជីវកម្មចែកបញ្ចាំងលួចលាក់ ។ល។ ហេតុនេះក្រសួង ឃោសនាការ និងវប្បធម៌ សូមជូនដំណឹងអំពីលក្ខការណ៍មួយចំនួនក្នុងការគ្រប់គ្រងអាជីវកម្មនាំចេញ នាំចូល និង ចែកបញ្ចាំងភាពយន្ត និង វីដេអូកាសែត ដូចខាងក្រោមនេះ :

*១- អំពីអាជីវកម្មនាំចូលភាពយន្ត និង វីដេអូ :*

ចាប់តាំងថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩០ តទៅ ក្រសួងឃោសនាការ និង វប្បធម៌ ទទួលត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការចំពោះតែភាពយន្ត ឬ វីដេអូកាសែតណាដែលក្រុមហ៊ុននាំចេញនាំចូល និង ចែកបញ្ចាំងបានធ្វើទំនាក់ទំនងទិញផ្ទាល់ពីក្រុមហ៊ុនចែកបញ្ចាំង ឬ ក្រុមហ៊ុនផលិតកម្មណាមួយនៅបរទេស ដែលមានអមជាមួយនូវលិខិតបញ្ជាក់ដែលចេញដោយក្រុមហ៊ុនបរទេសណា

Downloaded from http://www.khmerlaws.com

មួយដែលមានលក្ខណៈជាបទដ្ឋានក្នុងការលក់ផលិតផលភាពយន្ត ឬ វីដេអូ សម្រាប់ធ្វើអាជីវកម្មបញ្ចាំង ពោលគឺផ្អែកលើមូលដ្ឋាននៃការរក្សាសិទ្ធិផលិតផលភាពយន្ត ឬ វីដេអូ ។

ដោយសភាពការណ៍ប្រទេសជាតិរបស់យើងពុំទាន់មានទំនាក់ទំនងពាណិជ្ជកម្មផលិតផលវប្បធម៌ជាផ្លូវការជាមួយប្រទេសសេរីណាមួយនោះ និងក្នុងបំណងបំរើសំណូមពរមហាជន បណ្ដាក្រុមហ៊ុននាំចេញនាំចូល និងចែកបញ្ចាំងភាពយន្ត និង វីដេអូ អាចធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនចែកបញ្ចាំង ឬ ក្រុមផលិតកម្មនៅបរទេស ដើម្បីបញ្ជាទិញ និង នាំចូលភាពយន្ត ឬ វីដេអូតាខ្សែត ។

បណ្ដាខ្សែភាពយន្ត ឬ វីដេអូ ដែលនាំចូលសម្រាប់យកមកធ្វើអាជីវកម្មចាក់បញ្ចាំងត្រូវតែមានជាមួយនូវលិខិតបញ្ជាក់ការលក់ផលិតផលភាពយន្ត ឬ វីដេអូ ដែលចេញដោយក្រុមហ៊ុនចែកបញ្ចាំង ឬ ក្រុមហ៊ុនផលិតកម្មណាមួយនៅបរទេស ដោយមានការធានារ៉ាប់រងអំពីសិទ្ធិនិង គោលការណ៍ចែកបញ្ចាំងអាជីវកម្មនិងមានភ្ជាប់ជាមួយ ជាដាច់ខាតនូវបង្កាន់ដៃបង់ពន្ធនាំចូលដែលចេញដោយភ្នាក់ងារគយ ។

គោលការណ៍ដូចបានកំណត់ខាងលើនេះ នឹងត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩០ តទៅ ។

*២ - អំពីការនាំចេញ ភាពយន្ត និង វីដេអូ :*

រាល់ផលិតផលភាពយន្ត និង វីដេអូ ដែលត្រូវនាំចេញទៅក្រៅប្រទេសត្រូវមានការត្រួតពិនិត្យ និងចេញលិខិតអនុញ្ញាតពីក្រសួង ឃោសនាការ និង វប្បធម៌ ។

ចំពោះការនាំចេញផលិតផលភាពយន្ត ឬ វីដេអូ ដែលជាវណ្ណកម្មក្នុងស្រុក ឬ ផលិតផលដែលនាំចូលមកបញ្ចូលសម្លេងនៅក្នុងស្រុកនោះ ម្ចាស់ក្រុមហ៊ុននាំចេញនាំចូល ឬ ក្រុមហ៊ុនផលិតកម្មដែលជាម្ចាស់វណ្ណកម្មត្រូវធ្វើពាក្យសុំការត្រួតពិនិត្យ និង លិខិតអនុញ្ញាតនាំចេញពីក្រសួងឃោសនាការនិងវប្បធម៌ ។ ក្នុងករណីដែលក្រសួងឃោសនាការនិងវប្បធម៌បានដឹងថាវណ្ណកម្មរឿងក្នុងស្រុករបស់ផលិតកម្មណាមួយ ឬ ភាពយន្ត ឬ វីដេអូបរទេសដែលមានបញ្ចូលសម្លេងខ្មែររបស់ក្រុមហ៊ុនណាមួយ បានយកទៅបញ្ចាំងនៅបរទេស ដោយពុំមានការអនុញ្ញាតនាំចេញពីក្រសួងឃោសនាការ និងវប្បធម៌នោះ ត្រូវផលិតកម្មដែលជាម្ចាស់វណ្ណកម្មរឿង ឬ ក្រុមហ៊ុនដែលបាននាំចេញវណ្ណកម្មរឿងនោះ ត្រូវទទួលការពិន័យទ្វេមួយជាពីរលើតម្លៃ ដែលក្រសួងឃោសនាការ និង វប្បធម៌ បានកំណត់ក្នុងការត្រួតពិនិត្យផលិតផលភាពយន្ត ឬ វីដេអូដែលនាំចេញ ។ ក្នុងករណីមិនរាងចាលនឹងត្រូវដកហូតច្បាប់អនុញ្ញាតអាជីវកម្មនាំចេញនាំចូល ឬ ច្បាប់អនុញ្ញាតអោយ

Downloaded from http://www.khmerlaws.com

បង្កើតផលិតកម្ម ។ បទបញ្ញត្តិសេចក្តីជូនដំណឹងនេះ នឹងត្រូវអនុវត្តចាប់ពីថ្ងៃចេញផ្សាយដំណឹងនេះតទៅ

រដ្ឋមន្ត្រី ក្រសួងឃោសនាការ និង វប្បធម៌

ហត្ថលេខា និង ត្រា

ឆេង ផុន

Downloaded from http://www.khmerlaws.com

សហគ្រាសសម្ព័ន្ធរោងពុម្ព
បោះពុម្ពនៅរោងពុម្ពសុខាភិបាល
លើកទី ១ ចំនួន ៩.០០០ ច្បាប់

Downloaded from http://www.khmerlaws.com